# AMPACET | quality | គុណភាព

Ampacet គឺជាម្ចាស់ផ្គត់ផ្គង់គ្រាប់ពណ៌ សមាសធាតុផ្លាស្ទិច និងបណ្ដាសេវាសម្រាប់វិស័យឧស្សាហកម្មផ្លាស្ទិចក្នុងទូទាំងពិភពលោក។ Ampacet ធានានាំមកជូននូវបណ្ដាផលិតផល និងសេវាកម្មដ៏ល្អបំផុតតាមតម្រូវការ ឬលើសពីអ្វីអតិថិជនមិនអាចស្មានមុនបាន។ Ampacet ធានាជូន អតិថិជន ជាដៃគូ និងបណ្ដាបុគ្គលិកថា ពួកគេនឹងត្រូវបានប្រកបព្រមដោយយុត្តិធម៌ សច្ចធម៌ និង គុណធម៌។

---

### ការធានារបស់អគ្គនាយក

អគ្គនាយក Ampacet យល់ពីសារៈសំខាន់ និងតម្លៃនៃគុណភាព និងធានាពីប្រសិទ្ធិភាពនៃប្រព័ន្ធគ្រប់គ្រងគុណភាពរបស់ Ampacet។ អគ្គនាយក Ampacet នឹងប្រតិបត្តិការប្រកបដោយវិជ្ជាជីវៈ ផ្ដោតលើលទ្ធផលយូរអង្វែង និងបណ្ដាផ្នែកទំនាក់ទំនងផ្សេងៗរវាងដៃគូព្រោះតែផលប្រយោជន៍រួម។ Ampacet ចាត់ទុកថាម្ចាស់ផលិតផល និង អតិថិជនជាដៃគូសម្រាប់ក្នុងការសិក្សានិងកែលម្អ អានុញ្ញាតិឲ្យយើងខ្ញុំផ្គត់ផ្គង់បណ្ដាផលិតផល និងសេវាកម្មយូរអង្វែង បំពេញតាមសតម្រូវការអតិថិជន។ សមតាមតម្លៃជាគោលការណ៍ អគ្គនាយក យល់ថាវាគឺជាទិសដៅដ៏សមស្របសម្រាប់ការអានុវត្ត និងបន្តគោលការណ៍ដែលពាក់ព័ន្ធ។ Ampacet ធានាផ្គត់ផ្គង់ស្តង់ដារគុណភាពខ្ពស់ និងធានានូវអ្វីៗ ដែលបានសន្យា

---

### សុខភាព និងសុវត្ថិភាព

Ampacet ធានាថាជាក្រុមហ៊ុនមួយដែលប្រកបដោយបញ្ហាសុខនិងសុវត្ថិភាពជាចម្បងសម្រាប់កម្មករ។ យើងខ្ញុំយល់ថាសុវត្ថិភាព និងសុខភាពរបស់អ្នករាល់គ្នាគឺជាអាទិភាពដំបូងបំផុត ក៏ដូចជាអ្នកដែលប្រើប្រាស់ផលិតផលរបស់យើងខ្ញុំៈ បុគ្គលិក ដៃគូ ភ្ញៀវទស្សនា អតិថិជន និងអ្នកប្រើប្រាស់។ យើងខ្ញុំទទួលខុសត្រូវដោយវិធីបង្កើតជាបរិស្ថានដើម្បីការពារនៅកន្លែងធ្វើការប្រកបដោយសុវត្ថិភាព និងការប្រើប្រាស់សុវត្ថិភាពនៃបណ្ដាផលិតផលរបស់យើងខ្ញុំដូចជា ការវេចខ្ចប់ ការប៉ះពាល់ជាមួយអាហារ ការវេចខ្ចប់គ្រឿងសំអាង ការវេចខ្ចប់គ្រឿងអេឡិចត្រូនិក និងកម្មវិធីសំខាន់ផ្សេងៗទៀត។

---

### អតិថិជនជាចម្បង

យើងខ្ញុំឲ្យតម្លៃខ្ពស់បណ្ដាការផ្ដល់មតិរបស់អតិថិជន
ហើយតែងតែចង់ស្វែងយល់បន្ថែមទៀតអំពីតម្រូវការនិងគោលបំណងនៃអតិថិជន។ ជាមួយយើងខ្ញុំ ទំនុកចិត្តរបស់អតិថិជនគឺ អាស្រ័យលើសេវាកម្មគុណភាពខ្ពស់ និង ផលិតផលគួរដែលឲ្យទុកចិត្ត។ យើងខ្ញុំធានាជូនលោកអ្នកនូវគុណភាពដ៏ល្អបំផុត ចាប់តាំងពីផ្នែក រចនា ផលិត អាជីវកម្ម និងសេវាកម្ម។

---

### គុណសម្បត្តិដ៏សំខាន់

យើងខ្ញុំតែងតែលើកកំពស់ការសុវត្ថិភាព គុណភាព សច្ចភាព និង សុចរិតភាព ស្អិតរមួតនិងច្នៃប្រឌិត មិនលំអៀង ធ្វើការជាក្រុម និងចែករំលែកគ្នានូវចំណេះដឹងផ្សេងៗ ធ្វើការដោយយកចិត្តទុកដាក់បំផុត តែពោពេញទៅដោយភាពរីករាយ មានការយកចិត្តទុកដាក់ចំពោះបរិស្ថាន និងសកម្មភាពនៃអ្នកដែលនៅជិតខាង។
យើងខ្ញុំធានានូវការបណ្ដុះបណ្ដាលបណ្ដាបុគ្គលិកដើម្បីជំនួយដល់ពួកគាត់ ដើម្បី កែឲ្យមានភាពប្រសើរឡើង និង ធ្វើបច្ចុប្បន្នភាពនៃចំណេះដឹង។

យើងខ្ញុំបង្កើតជាបរិស្ថានធ្វើការងារដ៏តឹងរឹង ក៏ប៉ុន្តែ តែងតែមានរង្វាន់សម្រាប់បុគ្គលិកណាដែលគួរ នៅទីកន្លែងដែលយើងគ្រប់គ្នាអាចមានឱកាសដើម្បីអភិវឌ្ឍន៍ខ្លួនផ្ទាល់ ក៏ដូចជាការងារដែលបានតម្រូវឲ្យធ្វើ។

---

### គុណភាព

គុណភាពគឺជា កត្តាធ្វើឲ្យ Ampacet មានការផ្លាស់ប្ដូរ បើប្រៀបទៅជាមួយដៃគូរដែលកំពុងប្រកួតប្រជែង។
គុណភាណត្រូវបានស្ថាបនាឡើងចាប់តាំងពីការរចនា ផលិត និងចែកចាយបណ្ដាផលិតផល និងសេវាកម្មរបស់យើងខ្ញុំ។ មានការកែលម្អជារៀងរហូត នូវអ្វីដែលពាក់ព័ន្ធជាមួយការធ្វើការជាក្រុម និងការអនុវត្តន៍ដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិតដូចជាៈ

- -ការធ្វើសេចក្ដីសម្រេចចិត្តដោយផ្អែកទៅលើភស្តុតាងនិងការទទួលបានហានិភ័យ ដែលអាចកំបាំង
- -មានចំណេះដឹងជាមូលដ្ឋានក្នុងសកម្មភាពប្រកបដោយវិជ្ជាជីវៈ
- -កំណត់ដឹងច្បាស់ និងបង្ហាញច្បាស់នូវមូលហេតុនៃបញ្ហានោះៗ
- -រក្សាជំហរនៃការកែច្នៃដែលសម្រេចបាន។

---

### ចំពោះបរិស្ថាន

យើងខ្ញុំតែងតែមានសកម្មភាពលើស្មារតីទទួលខុសត្រូវដើម្បីការពារដល់បុគ្គលិក សហគមន៍ និង រក្សាការពារបរិស្ថានដែលនៅជុំវិញ។ យើងខ្ញុំនឹងបន្តខិតខំដើម្បីស្វែងរកមធ្យោបាយណាដ៏សមស្របបំផុតដើម្បីកែប្រែឲ្យមានភាពប្រសើរឡើង ប្រយោជន៍ដល់ការកាត់បន្ថយផលប៉ះពាល់ជាអប្បបរមាសម្រាប់បរិស្ថាន ក្នុងដំណើរការផលិត ក៏ដូចជាការបង្កើតឡើងជាផលិតផលដែលមិនប៉ះពាល់ដល់បរិស្ថាន សមស្របតាមបទបញ្ញត្តិនាពេលអនាគត។

---

01 March 2026

Alvaro Mendoza
President & Chief Executive Officer
Administration

Version 2.1